ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# សាររំលែកទុក្ខ

## ជូនចំពោះ
## លោកជំទាវ នាង លីណា និងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ មានសេចក្តីក្រៀមក្រំ និងសោកស្តាយជាពន់ពេក ដោយបានទទួលដំណឹងថា **លោក នាង ចំរើនវណ្ណៈ** ដែលត្រូវជាប្អូនប្រុសបង្កើតរបស់ **លោកជំទាវ នាង លីណា** បានទទួលមរណភាពកាលពីថ្ងៃចន្ទ ៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៤:០០នាទីរសៀល ក្នុងជន្មាយុ ៥៩ឆ្នាំ ដោយរោគាពាធ។

ក្នុងបរិយាកាសប្រកបដោយក្តីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមចូលរួមសម្តែងនូវមរណទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាទីបំផុតជាមួយ **លោកជំទាវ នាង លីណា និងក្រុមគ្រួសារ** ចំពោះការបាត់បង់ដ៏ធំធេងមិនអាចរកអ្វីមកប្រៀបបានមួយនេះ។

ខ្ញុំសូមឧទ្ទិសបួងសួងជូនដួងវិញ្ញាណក្ខន្ធ **លោក នាង ចំរើនវណ្ណៈ** បានអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោកជំទាវ នាង លីណា និងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីយើងខ្ញុំ។

ថ្ងៃ ៣៨ ៨ ៣២ ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០២៣

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ហ៊ុន ម៉ានី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# សេចក្តីជូនដំណឹង

ក្រសួងមុខងារសាធារណៈ សូមជម្រាបជូន **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់មេត្តាជ្រាបថា **លោក នាង ចំរើនវណ្ណៈ** ដែលត្រូវជាប្អូនប្រុសបង្កើត **លោកជំទាវ នាង លីណា** ទីប្រឹក្សានៃក្រសួងមុខងារសាធារណៈ ទទួលមរណភាពនៅថ្ងៃចន្ទ ៦រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ វេលាម៉ោង ០៤:០០នាទីរសៀល ក្នុងជន្មាយុ៥៩ឆ្នាំ ដោយរោគាពាធ។

**ឯកឧត្តម ហាច្យ ឆាំឆាន** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហ៊ុំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនឹងដឹកនាំប្រតិភូអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៧ថ្ងៃ នៅរសៀលថ្ងៃសៅរ៍ ទី១២ ខែសីហា ឆ្នាំ២០២៣ នៅវត្តអង្គលំទង ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** មេត្តាជ្រាបជាព័ត៌មាន និងចូលរួមរំលែកទុក្ខ ព្រមទាំងចាប់មគ្គផលតាមសទ្ធាជ្រះថ្លារៀងៗខ្លួន។

**NEANG LYNA មានគណនី ABA Bank ៖ 000 523 646**

ថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៣

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh